**មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក)**

ផ្ទះលេខ ១១៩ ផ្លូវ ២៥៧ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ

ប្រអប់សំបុត្រលេខ ១១១៨ ទូរស័ព្ទ: ៨៥៥-២៣-៨៨០ ៩១៦ ទូរសារ: ៨៥៥-២៣-៨៨៥ ១៤៦

# សេចក្តីប្រកាសព័ត៌មាន

*Released June 29, 2010*

## ការធានាឱ្យបានសំណាបថ្លោសល្អសំរាប់យកទៅស្ទូង

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក) ជាអង្គការមិនមែនរដ្ឋាភិបាលខ្មែរ ឯករាជ្យ មិនស្វែងរកកំរៃផលប្រយោជន៍បុគ្គល និងមិនពាក់ព័ន្ធគណបក្សនយោបាយ។ សេដាក បានត្រូវបង្កើតឡើងនៅឆ្នាំ ១៩៩៧ ក្នុងគោលបំណងពង្រឹងសមត្ថភាព និងភាពជាម្ចាស់របស់កសិករ ក្នុងការកែលំអគុណភាពជីវិតរបស់ខ្លួន និងចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សង្គម”។

ដើម្បីអោយស្រូវរបស់កសិករលូតលាស់បានល្អ នាំមកនូវផលខ្ពស់ **សំណាបថ្លោសល្អ** ជាកត្តាសំខាន់មួយ។ ដើម្បីអោយទទួលបានសំណាបថ្លោសល្អ មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក) សូមណែនាំអោយកសិករសាកល្បង អនុវត្តតាមបច្ចេកទេសទាំង ៩ ដូចខាងក្រោម:

១. រើសយកតែគ្រាប់ពេញសុទ្ធល្អ ទៅសាបដោយរើសចេញនូវគ្រាប់ដែលមានពណ៌ និងរាងខុសធម្មតាចោល។ កសិករអាចត្រូវចំណាយពេលច្រើនបន្តិចមែន តែការប្រើពូជសុទ្ធល្អនាំអោយកសិករទទួលបានផលច្រើន ហើយលក់ស្រូវបានតម្លៃថ្លៃទៀតផង។

២. យកគ្រាប់ ដែលរើសហើយទៅត្រាំជាមួយទឹកមានជាតិស្តៅ (ទឹកដែលត្រាំជាមួយគ្រាប់ សំបក ឬស្លឹកស្តៅ) ដើម្បីជួយការពារគ្រាប់ពីការបំផ្លាញពីសត្វល្អិតផ្សេងៗ។

៣. រៀបចំថ្នាលសំណាបគោក ដូចរងស្ពៃ ដើម្បីជៀសវាងកុំអោយសំណាបលិចទឹក ដែលនាំឱ្យវាលូតរាងវែង (លូតតែកំពស់ តែមិនសូវរីកទទឹង)។

៤. ប្រើជីកំប៉ុស្ត ឬជីមមោកព្រៃ (ដីស្រទាប់លើនៅក្នុងព្រៃ) ឬគុម្ពោតព្រៃឱ្យបានច្រើន។ ជីកំប៉ុស្តនាំឱ្យដីផុស ហើយសើមបានល្អ ដែលអំណោយផលដល់ការលូតលាស់របស់សំណាប។

៥. សាបស្តើងជាងធម្មតា ដើម្បីឱ្យដើមសំណាបនិមួយៗដុះរីកមាឌទទឹងបានល្អ (សំណាបថ្លោស)។

៦. ក្រោយពេលសាបហើយគ្របដីដោយប្រើស្លឹកឈើ (ប្រើទាំងស្លឹកទាំងមែក) ហើយដកស្លឹកឈើចេញពេលសំណាបចាប់ផ្តើមដុះ។

៧. ដកសំណាបនៅកន្លែងដែលចង្អៀតពេកចេញខ្លះ។

៨. ស្រោចទឹកបន្ថែម ប្រៀបដូចស្រោចកូនស្ពៃក្នុងករណីអត់មានភ្លៀង។ គេគួរលាយទឹក ជាមួយទឹកនោមគោក្នុងបរិមាណ ១:១០ (ទឹកនោម ដែលទុកឱ្យកាច់បានជាង ៧ថ្ងៃ) ដើម្បីជំរុញការលូតលាស់បន្ថែម។

៩. នៅពេលដកសំណាបទៅស្ទូង ដកតែដើមសំណាបថ្លោសជាងគេ ទៅស្ទូងបានហើយ ។

លោកបណ្ឌិតយ៉ង សាំងកុមារ ប្រធានអង្គការសេដាកមានប្រសាសន៏បញ្ជាក់បន្ថែមថា ក្នុងចំណោមបច្ចេកទេសទាំង ៩ ខាងលើនេះ កសិករអាចជ្រើសរើសមួយណាអនុវត្តក៏បានដែរ តែការផ្តុំចូលគ្នាបានច្រើនចំណុច នាំមកនូវផលល្អជាងការអនុវត្តបានតិចចំណុច ។ លោកបន្តថា ទោះក្នុងករណីយ៉ាងណាក៏ដោយ កសិករគួរអនុវត្តអោយបាននូវចំណុច ទី១ និងទី៩ គឺ**រើសតែគ្រាប់ល្អទៅសាប** និង**សំណាបថ្លោសទៅស្ទូង** ដែលអាចទទួលបានផលល្អ ។

**ទំនាក់ទំនង:** សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង លោក ហ៊ឹម ខទៀត: ០១៦ ៩៧៥ ៧១៣

Centre d'Etude et de Développement Agricole Cambodgien (CEDAC)

No 119 St. 257 Sangkat Teuk Laak 1, Khan Toul Kork, Phnom Penh - Cambodia
P.O.Box: 118, Tel.: 855-23-880 916, Fax: 855-23-885-146, E-mail: cedac@online.com.kh